**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១២៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃ សុក្រ ៤រោច ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃ សៅរ៍ ២ រោច ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃ ចន្ទ ១២រោច ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃ ចន្ទ ៤ កើត ខែ បុស្ស ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០២២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០២៣ | ឥណទាន មុនផ្ទេរ | ការផ្ទេរ | | ឥណទានថ្មី ក្រោយផ្ទេរ |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | ការផ្ទេរចេញ | | | | 49.033.600 | |
| | ៩៩-ចំណាយមិនទាន់បែងចែក មានមុខសញ្ញា | | | | 49.033.600 | |
| 69 | ចំណាយមិនបានគ្រោងទុក | 1.713.847.000 | 1.636.232.300 | - | 49.033.600 | 1.587.198.700 |
| | ការផ្ទេរចូល | | | 49.033.600 | | |
| | ០៥.១-ទីស្តីការគណៈរដ្ឋមន្ត្រី | | | 6.033.600 | | |
| 62 | អត្ថប្រយោជន៍សង្គម | 84.600.000 | 84.600.000 | 6.033.600 | - | 90.633.600 |
| | ០៩-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | | 2.207.000 | | |
| 60 | ការទិញ | 20.751.000 | 20.751.000 | 1.022.000 | - | 21.773.000 |
| 61 | សេវាកម្ម | 77.360.000 | 77.360.000 | 1.185.000 | - | 78.545.000 |
| | ១០-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | 40.000.000 | | |
| 65 | ឧបត្ថម្ភធន | 32.062.300 | 2.455.805.400 | 40.000.000 | - | 2.495.805.400 |
| | ១៤-ក្រសួងផែនការ | | | 243.000 | | |
| 61 | សេវាកម្ម | 10.450.400 | 34.882.400 | 243.000 | - | 35.125.400 |
| | ១៨-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | | 550.000 | | |
| 61 | សេវាកម្ម | 10.715.500 | 10.715.500 | 550.000 | - | 11.265.500 |

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់÷

១)-ផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រីចំនួន ៦ ០៣៣,៦ លានរៀល សម្រាប់ទូទាត់ចំណាយឧបត្ថម្ភ ភ្នាក់ងារសន្តិសុខ និងផ្គត់ផ្គង់ប្រេងឥន្ធនៈក្នុងកិច្ចដំណើរការរៀបចំពិនិត្យបញ្ជីឈ្មោះចុះឈ្មោះបោះឆ្នោត និងផ្តល់ សុពលភាពលើបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០២២។

២)-ផ្តល់ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ចំណាយមិនមែនបន្ទុកបុគ្គលិក ចំនួន ២ ២០៧ លានរៀល ដើម្បីចំណាយក្នុងកិច្ចដំណើរការស្ថានទូតកម្ពុជាប្រចាំនៅសាធារណរដ្ឋសហព័ន្ធប្រេស៊ីល។

៣)-ផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៤០ ០០០ លានរៀល សម្រាប់ចំណាយលើប្រតិបត្តិការរបស់មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព។

៤)-ផ្តល់ជូនក្រសួងផែនការចំនួន ២៤៣ លានរៀល សម្រាប់ផ្តល់ប្រាក់បេសកកម្មក្រៅប្រទេសជូនមន្ត្រីជាន់ខ្ពស់ គណៈប្រតិភូក្រសួងផែនការទៅចូលរួមកិច្ចប្រជុំនៅទីក្រុងដូហា ប្រទេសកាតា ទីក្រុងបាងកក ប្រទេសថៃ និងទីក្រុងញូយ៉ក សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០២៣។

៥)-ផ្តល់ជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចំនួន ៥៥០ លានរៀល សម្រាប់ចំណាយលើការជួសជុលដំបូលហោព្រះអង្គចេកព្រះអង្គចម និងការរៀបចំកែលម្អបរិស្ថានសំណង់ឡើងវិញ។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៩ រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ